

■ ប្រវត្តិអ្នកបម្រើរបស់ព្រះជាម្ចាស់ នៃព្រះសហគមន៍កាតូលិកកម្ពុជា **ទំព័រ៖ ៤-៩**

■ ឯកសារស៊ើបអង្កេតសម្រាប់មរណសាក្សីនៅកម្ពុជា បានទៅដល់ទីក្រុងរ៉ូម **ទំព័រ៖ ៣**




កាសែត
ចេញផ្សាយ
ប្រចាំខែ
ឆ្នាំទី១៤

# អ្នកនាំសារ the messenger

ខែសីហា | ឆ្នាំ ២០២៦ | លេខទី ១៦៣

www.catholiccambodia.org/ www.facebook.com/CatholicCambodia https:/khmer.rasia.org/

August 2026 | # 163




## អ្នកបម្រើរបស់ព្រះជាម្ចាស់ ទាំង១២រូប នៃព្រះសហគមន៍កាតូលិកកម្ពុជា

■ ការស៊ើបអង្កេតសម្រាប់មរណសាក្សីនៅកម្ពុជា បានបិទបញ្ចប់

**ទំព័រ៖ ២**



■ ព្រះវិហារថ្មីបំផុតនិងធំបំផុត នៅភូមិភាគភ្នំពេញមួយត្រូវបានឆ្លង

**ទំព័រ៖ ១០**



■ Ad Limna Visit ២០២៦ របស់លោកអភិបាលកាតូលិកឡាវ-កម្ពុជា

**ទំព័រ៖ ១១**



# ការស៊ើបអង្កេតសម្រាប់មរណសាក្សីនៅកម្ពុជាបានបិទបញ្ចប់



















ឯកសារដែលមានប្រមាណ ៦០០០ទំព័រ បានដាក់ដោយឡែកៗចំនួន៦កេះ ដែលទាក់ទងនឹងសំណុំរឿងស៊ើបអង្កេតសម្រាប់មរណសាក្សីនៅកម្ពុជា ត្រូវបានបិទជាស្ថាពរកាលពីពេលថ្មីៗនេះ ដោយលោកអភិបាលអូលីវីយេ ផ្មឹតហាស្លេ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល ភ្នំពេញថ្មី ដែលមានលោកអភិបាល លោកបូជាចារ្យ និងគ្រីស្តបរិស័មកពីភូមិភាគទាំងបី របស់ព្រះសហគមន៍កាតូលិក ជិត៣០០ នាក់ចូលរួម។

លោកអភិបាល អូលីវីយេ ផ្មឹតហាស្លេ អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ បានប្រកាសយ៉ាងឱឡារិកកាលពីថ្ងៃទី១៨ ខែមីនានេះថា «ការស៊ើបអង្កេតអំពីអ្នកបម្រើរបស់ព្រះជាម្ចាស់... បានបិទហើយ»។

លោកឲ្យដឹងថា អ្នកបម្រើរបស់ព្រះជាម្ចាស់ទាំងនេះ ជាគំរូនៃជំនឿនិងជាក្តីសង្ឃឹមសម្រាប់ព្រះសហគមន៍ជំនាន់នេះ និងជំ នាន់ក្រោយៗ ដោយពួកគាត់បានផ្តល់សក្ខីកម្មយ៉ាងជាក់ស្តែង នាំឲ្យយើងមានជំនឿ បន្តអធិដ្ឋាន និងបន្តយកចិត្តទុកដាក់បង្ហាញ មេត្តាករុណារបស់ព្រះ ជាម្ចាស់ ចំ ពោះគ្នាទៅវិញទៅមក និងចំពោះអ្នកដទៃ។ លោកអភិបាលអូលីវីយេ ជាអភិបាលគ្រប់គ្រងដំណើរការតុលា ការស៊ើបអង្កេត មរណសាក្សីនេះមានប្រសាសន៍ថា ការស៊ើបអង្កេតនេះ ចាបផ្តើមតាំងពីឆ្នាំ២០១៥មក ក្រោយសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានចេញលិខិតអនុញ្ញាត ឲ្យព្រះសហគមន៍កម្ពុជា អាចប្រមូលឯកសារ និងស៊ើបអង្កេត ចំពោះអ្នកដែលបានបូជាជីវិត ក្នុងពេលមានសង្គ្រាមនៅកម្ពុជា។ ក្នុងរយៈពេលនេះ តុលាការបានបើកសំណុំរឿងធំៗ ចំនួន២២ដង និងបានជួបសាក្សីជាច្រើន។ លោកអភិបាលសង្ឃឹមថា «នៅពេលអនាគត យើងមានដំណឹងល្អ និងព្រះសហ គមន៍ទាំងមូល ហើយគោរពសាក្សីរបស់យើង និងទទួលកម្លាំងថែមទៀត និងជាពិសេសសម្រាប់ព្រះសហគមន៍កាតូលិកកម្ពុជារបស់យើងជំនាន់ថ្មីៗ ដែលអត់បានស្គាល់ ប៉ុល ពត ដែលអត់បានស្គាល់ទុក្ខលំបាកដែលស្គាល់សន្តិភាពសព្វថ្ងៃ ឱ្យយើងបន្តថែរក្សាសន្តិភាពនេះ និងបន្តតស៊ូក្នុងជំនឿរបស់យើង ដើម្បីទៅជាសាក្សីតៗទៅទៀត។» លោកបូជាចារ្យប៉ូល រឿងឆ័ត្រសិរី អ្នកប្រមូលសំណុំរឿងឲ្យដឹងថា កាលពីថ្ងៃទី១៨ ខែមីនាថា ឯកសារដែលបានដាក់ទៅនោះ មាន២ផ្នែកសំខាន់ៗ គឺមានឯកសារអំពីតុលាការ និងឯកសារអំពីប្រវត្តិ របស់អ្នកបម្រើ របស់ព្រះជាម្ចាស់ទាំង១២រូបនោះ។

លោកបូជាចារ្យឆ័ត្រសិរី បន្តថាការស៊ើបអង្កេតនេះ មានសេចក្តីណែនាំពីក្រសួងសន្តបុគ្គលនិងអ្នកមានសុភមង្គលពីទីក្រុងរ៉ូម។ ក្រសួងនេះបានចេញឯកសារណែនាំដើម្បីឱ្យយើងបានដឹង របៀបនៃការស៊ើបអង្កេត ដូច្នេះយើងព្យាយាមមែនទែន ដើម្បីដើរតាមផ្លូវនេះ ក៏ដូចជាការបង្កើតតុលាការ ការបង្កើតអ្នកដែលពាក់ព័ន្ធ នៃទទួលខុសត្រូវ របៀបនៃការបើកតុលាការ ឬក៏របៀបនៃការប្រមូលឯកសារហើយរៀបចំឯកសារទាំងអស់ដើម្បីបន្តការស៊ើបអង្កេត។ លោកបូជាចារ្យវ៉ាំងសង់ ច្រេចទៀន អ្នកប្រមូលឯកសារ ផ្នែកប្រវត្តិសាស្ត្រនិយាយ ថាឯកសារប្រវត្តិរបស់មរណសាក្សីនីមួយៗ ត្រូវការពេលវេលាជាច្រើន ដើម្បីចងក្រងហើយខ្លះ អាចដល់ទៅ៦ខែ ដើម្បីទទួលបានឯកសារមួយពេញលេញ។ ប្រភពឯកសារទាំងនោះ ត្រូវបានយកមក ពីប្រទេសជាច្រើនដូចជា បារាំង ទីក្រុងរ៉ូម ម៉ាឡេស៊ី វៀតណាម ចំណែកឯកសារនៅ ក្នុងប្រទេសកម្ពុជាយើងពិបាករក ដោយសារសម័យប៉ុលពតបានបំផ្លាញអស់គ្មានសល់។ លោកវ៉ាំងសង់ បន្តថា «ក្នុងនាមជាសមាជិកតុលាការរៀបចំឯកសារ យើងបានបោះលេខរៀងលើគ្រប់ទំព័រ ហើយលោកពុកយ៉ាំងលូកា បានចុះហត្ថលេខា លើគ្រប់ឯកសារទាំងអស់។ បន្ទាប់មក លោកអភិបាលអូលីវីយេ នឹងបោះត្រាបញ្ជាក់ ដើម្បីធានាថាគ្មាននរណាម្នាក់អាចបន្ថែមបន្ថយ ឬកែប្រែខ្លឹមសារបានឡើយ។ ការធ្វើបែបនេះ គឺដើម្បីប្រកាសជាផ្លូវការ មុននឹងបញ្ជូនទៅទីក្រុងរ៉ូមថា ឯកសារយើងស្អាតស្អំ និងគ្មានការភូតកុហក។» អ្នកបម្រើរបស់ព្រះជាម្ចាស់មានចំនួន១២រូបរួមមាន៖ លោកអភិបាល យ៉ូសែបឆ្មារ សាឡាស់ លោកបូជាចារ្យ យ៉ូសែប ឆ្មារសាឡឹម លោកបូជាចារ្យ ម៉ាសែល ទ្រឿងសាងសំរើន លោកបូជាចារ្យ សិលា វ៉ាប៉ាំង បងប្រុសដាមីយ៉ាំង ដាំង ង៉ុក អាំងលោកបូជាចារ្យ យ៉ូហាន បាជ្រេ បងស្រីហ្សាកឺលីន សួន បងស្រី លីឌី នូសាវ៉ាន់ លោកយ៉ូសែប សំ គីមសាន លោក យ៉ូសែប ថុង លោក សិលា ឈុំសំថៃ និងលោក យ៉ូសែប រស់ អេន។ អស់លោកបានទទួលមរណភាព កាលពី៥០ឆ្នាំមុន ក្នុងអំឡុងពេល ប្រទេសកម្ពុជាបានធ្លាក់ក្នុងភ្លើងសង្គ្រាមដែលត្រូវបានចាត់ទុកថាជាឆ្នាំសូន្យ ដែលគ្មានការអនុញ្ញាតគោរពប្រណិប័តន៍សាសនា និងរស់នៅដោយរងទុក្ខវេទនា ភ័យខ្លាច អត់អាហារ និងធ្វើការងារលើសកម្លាំង។ លោកអភិបាលជាតិខ្មែរ និងសហការី របស់លោកបានតស៊ូរួមជាមួយជំនឿ ហើយត្រូវបានស្លាប់និងត្រូវសម្លាប់ ដូចប្រជាជនខ្មែរជិត២លាននាក់ដែរ។ ក្រោយឆ្នាំ១៩៩០ ព្រះសហគមន៍ចាប់ផ្តើមរស់រានឡើងវិញក្រោមការណែនាំរបស់សាសនទូត និងបានរីកចម្រើនរហូតមកដល់ពេលនេះ។

បច្ចុប្បន្នមានគ្រីស្តបរិស័ទចំនួន២ម៉ឺននាក់ បូជាចារ្យខ្មែរចំនួន១៣អង្គ និងបព្វជិត២អង្គ បព្វជិតាជិត២០នាក់ ដែលកំពុងបម្រើការងារ ក្នុងចំណោមសាសនទូតប្រមាណ១៥០ នាក់ដែលមកពីប្រទេសជាច្រើន៕

កែវ កញ្ញា

# ឯកសារស៊ើបអង្កេតសម្រាប់មរណសាក្សីនៅកម្ពុជា បានទៅដល់ទីក្រុងរ៉ូម

ឯកសារស៊ើបអង្កេតសម្រាប់មរណសាក្សីនៅកម្ពុជា ដែលបានបិទបញ្ចប់ បានទៅដល់ ក្រសួងកិច្ចការសន្តបុគ្គល កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៦ ដោយ ក្រុមសភាលោកអភិបាលកាតូលិក ឡាវ-កម្ពុជា ក្នុងដំណើរទស្សនកិច្ច Ad Limina Visit ទៅកាន់ទីក្រុងរ៉ូម។ ក្រសួងសាម៉ីនឹងត្រួតពិនិត្យ បន្ទាប់មកនឹងបញ្ជូនថ្វាយ សម្តេចប៉ាប ឡេអូទី១៤ ដើម្បីសម្រេចនិងអនុម័ត។

ក្នុងជំនួបនោះ លោកអភិបាល អូលីវីយេ ពន្យល់ថា «ឯកសារទាំងនេះ មិនត្រឹមតែ រៀបរាប់ពីជីវិត និងការបូជាដ៏ថ្លៃថ្លារបស់ពួកលោក អ្នកទាំងនោះប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាកេរដំណែល ខាងវិញ្ញាណដ៏មហា សាលសម្រាប់ព្រះសហគមន៍កាតូលិក និងសម្រាប់ពិភពលោកផងដែរ»។ នៅពេលប្រគល់ឯកសារ ទៅឱ្យក្រសួងកិច្ចការសន្តបុគ្គល លោកអភិបាល បានសម្តែង ក្តីសង្ឃឹមថា «ការពិនិត្យនិងការវិនិច្ឆ័យអាចបន្តទៅមុខ ដើម្បីឱ្យអ្នកបម្រើព្រះជាម្ចាស់ទាំងនេះ ឆាប់ទទួលស្គាល់ និងដាក់ឲ្យគោរពជាផ្លូវការណ៍សម្រាប់ព្រះសហគមន៍ សកលលោក ដែលជាអំណោយ និងជា សក្ខីកម្មដ៏ត្រចះត្រចង់»។ លោកអភិបាល បន្ថែមថា «ព្រះសហគមន៍កាតូលិករបស់យើងនៅកម្ពុជា មានសេចក្តីរីករាយ។ វិញ្ញាណ និងការបំផុសគំនិត របស់មរណសាក្សី មានសារៈសំខាន់ខ្លាំងណាស់ ពួក គេគឺជាកម្លាំងចិត្តដ៏អស្ចារ្យសម្រាប់យើង។

សហគមន៍របស់យើង នឹងរួបរួមគ្នាក្នុងការ អធិដ្ឋាន ដើម្បីឱ្យបុព្វហេតុនេះអាចរីកចម្រើនទៅតាមផែនការ របស់ព្រះជាម្ចាស់ តាមរយៈការងារនៅបុរីវ៉ាទីកង់»។ លោកមានគម្រោងបន្តសកម្មភាព ដើម្បីជួយអោយគ្រីស្តបរិស័ទ ក្នុងប្រទេសកម្ពុជាយល់អំពីអ្នកបម្រើព្រះជាម្ចាស់ ក្នុងពេលជាមួយគ្នានេះ យើងនឹងបន្តលើកកម្ពស់ការយល់ដឹង ជាពិសេសក្នុងចំណោមយុវជន អំពីរឿងរ៉ាវនៃអ្នកបម្រើព្រះជាម្ចាស់របស់យើង ដោយការបោះពុម្ពខិត្តប័ណ្ណ និងរៀបចំព្រឹត្តិការណ៍វប្បធម៌ការបង្រៀនសាសនា និងការអធិដ្ឋាន។ យើងសង្ឃឹម និងអធិដ្ឋានថាគំរូរបស់ពួកគេនឹងបង្កើតផល និងនាំមកនូវព្រះគុណនិងភាពវិសុទ្ធ ដល់ព្រះសហគមន៍ តូចរបស់យើងសម្រាប់អនាគត៕

(Fides News)







# ប្រវត្តិអ្នកបម្រើរបស់ព្រះជាម្ចាស់ទាំង១២រូប នៃព្រះសហគមន៍កាតូលិកកម្ពុជា



## លោកអភិបាល យ៉ូសែប ឆ្មារ សាឡាស់

អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

(១៩៣៧ - ១៩៧៧)

លោកយ៉ូសែប ឆ្មារ សាឡាស់ ជាអ្នកភូមិមាត់ក្រសាស់ កើតនៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៣៧ នៅព្រះសហគមន៍ក្នុងភូមិមាត់ក្រសាស់ ជិតរាជធានីភ្នំពេញ ក្នុងគ្រួសារកាតូលិកមួយ ដែលមានជីវភាពមធ្យម ឪពុករបស់គាត់ជាជាងបោះពុម្ពអក្សរ ម្តាយជាមេគ្រួសារ។ លោកជាកូនទី៣ ក្នុងចំណោមបងប្អូនទាំងអស់៨នាក់ ហើយបានទទួលការណែនាំជំនឿដ៏រឹងមាំពីក្រុម គ្រួសារ។ បានចូលរៀននៅអនុទេវវិទ្យាល័យនៅផ្សារតូច នាទីក្រុងភ្នំពេញ។

នៅឆ្នាំ១៩៥៨ លោកអភិបាល យ៉ូហាន បាទីស្ត ម៉ាស៊ីមីឡង់ ឆាបាលីយ៉េរ បានសម្រេចបញ្ជូនលោក ទៅបន្តការសិក្សានៅអនុទេវវិទ្យាល័យ សន្តរ៉ុក (Saint Roch) ប្រទេសបារាំង។ និងបន្តនៅទេវវិទ្យាល័យ នៅអ៊ីស៊្សី-លេ-មូលីណូ (Issy-les-Moulineaux) ហើយទទួលការតែងតាំងជាបូជាចារ្យនៅឆ្នាំ១៩៦៤ នៅអាសនៈវិហារ "ព្រះគ្រីស្តជាព្រះមហាក្សត្រ” នៅទីក្រុងភ្នំពេញ។ ដោយលោកអភិបាល លោកអភិបាល អ៊ីវ រ៉ាមូស លោកបម្រើការងារនៅបាត់ដំបង និងនៅអាសនៈវិហារនៅភ្នំពេញ ជាមួយលោកអភិបាលរ៉ាមូស។ នៅឆ្នាំ១៩៧៤ លោកទៅរៀនបន្ថែមនៅបារីស ប្រទេសបារាំង។ ឆ្នាំ១៩៧៥ លោកត្រូវហៅត្រឡប់មកទីក្រុងភ្នំពេញវិញ ដោយដឹងថាការត្រឡប់មកលើកនេះគឺដើម្បីស្លាប់ តែលោកសម្រេចចិត្តដោយសេចក្តីក្លាហាន។

លោកបានទទួលអគ្គសញ្ញាតែងតាំងជាអភិបាល នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥ នៅព្រះវិហារ «ព្រះនាងម៉ារីគ្មានជំពាក់បាប» (ភូមិព្រះមាតា) ក្នុងស្ថានភាពកំពុងមានសង្គ្រាមដ៏សែនពិបាកបំផុត។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកត្រូវបានបណ្តេញចេញពីរាជធានីភ្នំពេញ ជាមួយប្រជាជនទាំងមូល ដោយធ្វើដំណើរថ្មើរជើងដល់ភូមិតាំងគោក ក្នុងអំឡុងដំណើរដោយបង្ខំនេះ លោកបានឈឺជាច្រើនលើកដោយសារខ្វះម្ហូបអាហារយ៉ាងធ្ងន់ធ្ងរ។ លោកអភិបាល យ៉ូសែបឆ្មារ សាឡាស់ បានទទួលមរណភាព នៅខែកញ្ញា ឆ្នាំ១៩៧៧ នៅវត្តថ្លា ភូមិតាំងគោក ដែលជាមន្ទីរពេទ្យបណ្តោះអាសន្ន។ គុណធម៌ដ៏សំខាន់ របស់លោកអភិបាល យ៉ូសែប ឆ្មារ សាឡាស់ គឺចិត្តដូចគង្វាល សុខចិត្តរងទុក្ខរួមជាមួយបងប្អូន ដើម្បីជួយផ្តល់កម្លាំងដល់ពួកគេ ដែលជាហ្វូងចៀមរបស់លោក៕



## លោកបូជាចារ្យ យ៉ូសែប ឆ្មារ សាឡឹម

បូជាចារ្យភូមិភាគភ្នំពេញ

(១៩៤០-១៩៧៧)

លោកបូជាចារ្យ យ៉ូសែប ឆ្មារ សាឡឹម កើតនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៤0 នៅភូមិមាត់ក្រសាស់ ក្នុងគ្រួសារគ្រីស្តបរិស័ទដែលមានជំនឿ ម្តាយរបស់លោកមានទម្លាប់នាំកូនៗ ចូលរួមអភិបូជារៀងរាល់ថ្ងៃ។ លោកជាប្អូនរបស់លោកអភិបាល យ៉ូសែប ឆ្មារ សាឡាស់។ ក្រោយមកគ្រួសាររបស់លោក ផ្លាស់ប្តូរទីលំនៅទៅជិតភូមិព្រះមាតា ជិតព្រះវិហារកាតូលិក នៅទីក្រុងភ្នំពេញ។ បន្ទាប់ពីបញ្ចប់ការសិក្សាកម្រិតបឋម និង មធ្យមសិក្សានៅអនុទេវវិទ្យល័យភ្នំពេញ លោកមានចំណាប់អារម្មណ៍ចង់ក្លាយជាបូជាចារ្យ បន្ទាប់មកលោកអភិបាល ហ្គោស្តាវ រ៉ាបាឡង់ (Gustave Raballand, Mep) បានបញ្ជូនលោក ទៅប្រទេសបារាំង នៅឆ្នាំ ១៩៦២ ដើម្បីបន្តការបណ្តុះបណ្តាលនៅទេវវិទ្យាល័យ អ៊ីស៊្សី-លេ-មូលីណូ (Issy-les-Moulineaux)។ លោកបានទទួលអគ្គសញ្ញាតែង តាំងជាបូជាចារ្យ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៦៧ នៅអាសនៈវិហារព្រះនាងម៉ារី នាទីក្រុងប៉ារីស ដោយលោកអភិបាលVeuillot។ ពេលលោកត្រឡប់មកម្ពុជាវិញ ត្រូវបានចាត់តាំងជាលោកជំនួយចៅអធិការនៅអាសនៈវិហារ "ព្រះគ្រីស្តជាព្រះមហាក្សត្រ" នៅភ្នំពេញ។ បន្ទាប់មកលោកបានទទួលខុសត្រូវព្រះសហគមន៍នៅភូមិមាត់ក្រសាស់ និង ជាលេខារបស់លោកអភិបាល។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ លោក យ៉ូសែប ឆ្មារ សាឡឹម មានចិត្តដូចគង្វាល ថែរក្សា ដឹកនាំព្រះសហគមន៍ ទោះបីក្នុងស្ថានភាពសង្គ្រាម។ ពេលត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ លោក ឆ្មារ សាឡឹម ចេញទៅជាមួយក្រុមលោកអភិបាល ឆ្មារ សាឡាស់ និងលោកឪពុក ម៉ាសែល ទ្រឿង សាង សំរើន ជាមួយដូនជី៦នាក់ និងកុមារកំព្រា ដោយថ្មើរជើងទៅដល់ភូមិតាំងគោក។ ក្នុងស្ថានភាពលំបាកនោះ មានពេលខ្លះ លោករួមជាមួយក្រុមគ្រួសារ បានថ្វាយអភិបូជាដោយស្ងាត់ៗ ដើម្បីលើកទឹកចិត្តនិងពង្រឹងជំនឿរបស់អ្នកជិតខាង។ ក្នុងអំឡុងឆ្នាំ១៩៧៧ លោកបូជាចារ្យ យ៉ូសែប ឆ្មារ សាឡឹម ត្រូវរងទុក្ខដោយ ភាពអត់ឃ្លាន និងធ្វើការយ៉ាងធ្ងន់។ លោកស្ម័គ្រចិត្តចូលកងចល័តតំបន់ ជាមួយលោកឪពុក ទ្រឿង សាង សំរើន ដោយសង្ឃឹមជួយរកគ្រីស្តបរិស័ទ ប៉ុន្តែលោកបាត់ខ្លួនចាប់ពីពេលនោះមក៕



រូបថត របស់លោក យ៉ូសែប ឆ្មារសាឡាស់



ភូមិព្រះមាតា



## លោកបូជាចារ្យ ម៉ាសែល ទ្រឿង សាង សំរើន

បូជាចារ្យភូមិភាគភ្នំពេញ

(១៩៤០-១៩៧៧)

លោកបូជាចារ្យ ម៉ាសែល ទ្រឿង សាង សំរើន កើតនៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៤៤ នៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង ក្នុងគ្រួសារក្រីក្រដែលមានបងប្អូនប្រាំមួយនាក់។ លោកមានការសិក្សាល្អ និងអាចប្រើភាសាខ្មែរ និងវៀតណាមបានយ៉ាងស្ទាត់។ បន្ទាប់ពីបញ្ចប់ការសិក្សានៅកំពង់ត្របែក លោកបានចូលអនុទេវវិទ្យាល័យសន្តយ៉ូសែប ភ្នំពេញ ហើយបង្ហាញបំណងចង់ក្លាយជាបូជាចារ្យ ទោះបីឪពុកម្តាយជំទាស់ក៏ដោយ។ នៅឆ្នាំ១៩៦៥ លោកបានចូលទេវវិទ្យាល័យភ្នំពេញ ដើម្បីសិក្សាទស្សនវិជ្ជា ហើយនៅឆ្នាំ១៩៦៧–១៩៦៨ បានជួយបម្រើនៅព្រះសហគមន៍មាត់ក្រសាស់។ បន្ទាប់មក លោកបានចូលរួមកម្មវិធីសិក្សាឈ្វេងយល់អំពីប្រទេសកម្ពុជា ដើម្បីជួយនិស្សិតដែលមានដើមកំណើតវៀតណាម ឱ្យស្គាល់ និងសម្របខ្លួនទៅនឹងវប្បធម៌ខ្មែរ។ នៅឆ្នាំ១៩៦៩ លោកបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកទស្សនវិជ្ជានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីត្រៀមខ្លួនសម្រាប់ជីវិតជាបូជាចារ្យ។ ប៉ុន្តែ រដ្ឋប្រហារខែមីនា ឆ្នាំ១៩៧០ បានធ្វើឱ្យទេវវិទ្យាល័យភ្នំពេញបិទទ្វារ។ ដូច្នេះ លោកអភិបាល អ៊ីវ រ៉ាមូស (Yve Ramousse) ចាត់លោកឱ្យទៅបន្តការសិក្សានៅទេវវិទ្យាល័យកោះប៉េណាំង ប្រទេសម៉ាឡេស៊ី ដែលលោកបានចូលរៀននៅខែកុម្ភៈ ឆ្នាំ១៩៧១។

លោកបូជាចារ្យ ម៉ាសែល ទ្រឿង សាង សំរើន ត្រូវបានតែងតាំងជាបូជាចារ្យនៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៤ នៅអាសនៈវិហារ «ព្រះគ្រីស្តជាព្រះមហាក្សត្រ» ភ្នំពេញ។ លោកត្រូវបានចាត់ឱ្យបម្រើជាបូជាចារ្យជំនួយនៅព្រះសហគមន៍ព្រះនាងម៉ារីគ្មានជំពាក់បាប។ ដោយមានចិត្តស្លូតបូត អត់ធ្មត់ និងយកចិត្តទុកដាក់ចំពោះគ្រីស្តបរិស័ទ និងអ្នកជំងឺ លោកបានបង្ហាញចិត្តគង្វាលយ៉ាងជ្រាលជ្រៅ។ នៅឆ្នាំ១៩៧៥ ក្នុងពេលប្រទេសកម្ពុជាជួបសង្គ្រាម លោកបានសម្រេចចិត្តនៅជាមួយប្រជាជន ដោយមានប្រសាសន៍ថា៖ «យើងទាំងអស់គ្នា ដែលថ្វាយខ្លួនជាបូជាចារ្យ ជាអ្នកបួស ឬជាដូនជីគឺមិនមែនដើម្បីរត់គេចយករួចខ្លួន ក្នុងពេលដែលប្រទេសខ្មែរ កំពុងជួបមហន្តរាយនោះទេ»។ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ភ្នំពេញ ឆ្នាំ១៩៧៥ លោកត្រូវបានជម្លៀសទៅជនបទ និងបង្ខំធ្វើការដូចប្រជាជនទូទៅ ទោះមានជំងឺភ្នែក និងខ្វះអាហារក៏ដោយ។ លោកនៅតែរក្សាជំនឿ អធិដ្ឋាន និងពេលខ្លះថ្វាយអភិបូជាដោយស្ងាត់ៗ។ នៅឆ្នាំ១៩៧៧ ដោយសារការសង្ស័យរបស់ខ្មែរក្រហម លោកត្រូវបាននាំទៅសម្លាប់ជាមួយលោកបូជាចារ្យ ឆ្មារ សាឡឹម។ មុនពេលទទួលមរណភាព លោកបានប្រគល់ជីវិតទាំងស្រុងទៅព្រះជាម្ចាស់ ដោយនិយាយថា៖ «សូមឱ្យព្រះហឫទ័យរបស់ព្រះអម្ចាស់បានសម្រេច» និងច្រៀងធម៌ «ឱ! ព្រះបិតា»។



## លោក យ៉ូសែប រស់ អេន

គ្រូអប់រំជំនឿ

(១៩៤០-១៩៧៧)

លោក យ៉ូសែប រស់ អេន កើតនៅថ្ងៃទី២០ ខែកម្ភៈ ឆ្នាំ ១៩៤១ នៅភូមិកំពង់គោ ខេត្តកំពង់ធំ ជាកូនច្បងក្នុងគ្រួសារក្រីក្រមួយ ដែលមានបងប្អូនចំនួន៩នាក់។ លោកទទួលអគ្គសញ្ញាជ្រមុជទឹក នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំដដែល នៅក្នុងព្រះវិហារសន្តីតេរេសា កំពង់គោ។ លោកមានជីវិតជាប់ចិត្តនឹងព្រះវិហារតាំងពីកុមារភាព ដោយតែងតែចូលរួមពិធីបុណ្យ ដូចជាទៅអភិបូជាជារៀងរាល់ថ្ងៃនិងអធិដ្ឋាន។ នៅឆ្នាំ១៩៥៣ លោកឪពុក រ៉ូប៊ែរ វឺណេ (Robert Venet) ទទួលខុសត្រូវព្រះសហគមន៍នៅទីនោះ បញ្ជូនលោកឲ្យចូលអនុទេវវិទ្យាល័យ នៅផ្សារតូច ទីក្រុងភ្នំពេញ ហើយគាត់បានបន្តការសិក្សានៅទីនោះអស់រយៈពេលដប់ឆ្នាំ។

ជាសិស្សមានវិន័យ និងខិតខំប្រឹងប្រែង ទោះជាយ៉ាងណា រស់ អេន ក៏បានជួបការលំបាកខ្លះៗក្នុងការសិក្សា។ នៅឆ្នាំ១៩៦៤ លោកបានចូលរៀនទេវវិទ្យាល័យ នៅប៉េណាំង (Penang) ប្រទេសម៉ាឡេស៊ី។ លោកចំណាយពេលជួយព្រះសហគមន៍នៅពេលវិស្សមកាល លោកមកសួរសុខទុក្ខអ្នកភូមិ និងជួយធ្វើការងាររបស់ពួកគេដោយផ្ទាល់ ឬ ជួយកិច្ចការទាំងអស់ដែលអាចធ្វើបាន ដូចជាការហាត់ចម្រៀង ការរៀបចំបុណ្យធំៗជាដើម។

ក្រោយពីពិចារណា និងឈ្វេងយល់អំពីការត្រាស់ហៅរបស់ព្រះអម្ចាស់ លោកបានសម្រេចចិត្តចេញពីទេវវិទ្យាល័យ ដោយយល់ឃើញថា ព្រះអម្ចាស់មិនបានហៅគាត់ឲ្យទៅជាបូជាចារ្យទេ។ បន្ទាប់ពីនោះមក លោកបានធ្វើជាសាស្ត្រាចារ្យបង្រៀនភាសាអង់គ្លេសនៅសាកលវិទ្យាល័យ។ ហើយបានរៀបអាពាហ៍ពិពាហ៍ ជាមួយស្ត្រីម្នាក់ដែលបានប្រែចិត្តជាគ្រីស្តបរិស័ទ។ លោកបានត្រឡប់មកនៅភូមិកំពង់គោ ក្នុងតួនាទីជាគ្រូបង្រៀនបឋមសិក្សា។

នៅឆ្នាំ ១៩៧៧ រស់ អេន ត្រូវបានស្គាល់អត្តសញ្ញាណដោយអតីតមិត្តរួមថ្នាក់ពីសាកលវិទ្យាល័យ។ ដូច្នេះលោកបានប្រកាសជាសាធារណៈ មុខខ្មែរក្រហមថា៖ លោកជាគ្រីស្តបរិស័ទ និងជាគ្រូបង្រៀន។ នៅពេលនោះ លោកត្រូវហៅទៅ «រៀនសូត្រ» និងយកទៅសម្លាប់នៅថ្ងៃនោះ។ សម្លៀកបំពាក់របស់ រស់ អេន ត្រូវបានចែកឲ្យគ្រួសារខ្មែរក្រហមនៅថ្ងៃបន្ទាប់។ គុណធម៌ដ៏សំខាន់របស់លោកគឺ ការខិតខំបំពេញការងារក្នុងព្រះសហគមន៍ក្នុងឋានៈជាគ្រហស្ថ ជួយអប់រំជំនឿ បម្រើកិច្ចការសង្គហៈ និងផ្តល់សក្ខីភាពជាគ្រីស្តបរិស័ទ ទោះបីត្រូវគេបៀតបៀន៕



អនុទេវវិទ្យាល័យសន្តយ៉ូសែប ផ្សារតូច ភ្នំពេញ



ទេវវិទ្យាល័យ នៅប៉េណាំង (Penang) ប្រទេសម៉ាឡេស៊ី



## បងប្រុស ដាមីយ៉ាំង ដាំង ង៉ុក អាំង

បព្វជិតនៃក្រុមបងប្រុសគ្រួសារដ៏វិសុទ្ធ

(១៩១២ - ១៩៧៨)

បងប្រុស ដាមីយ៉ាំង ដាំង ង៉ុក អាំងកើតនៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ១៩១២ នៅភូមិបាណាម ខេត្តព្រៃវែង។ ពេលគាត់អាយុ២០ឆ្នាំ គាត់ចូលរៀនដើម្បីបួសក្នុងក្រុមបងប្រុសគ្រួសារដ៏វិសុទ្ធ នៅបាណាម។ នៅឆ្នាំ១៩៣៥ គាត់ធ្វើសច្ចាលើកដំបូង នៅចំថ្ងៃបុណ្យព្រះនាងម៉ារីឡើងស្ថានបរមសុខ។ គាត់រស់នៅក្នុងអារាមរយៈពេល១៣ឆ្នាំ។ គាត់មានចិត្តមេត្តាករុណា យកចិត្តទុកដាក់ចែករំលែកដល់អ្នកក្រីក្រ។ ប៉ុន្តែ ដោយគាត់ក៏ចង់បម្រើដល់ប្រជាជនខ្មែរ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៤៨ គាត់បានទទួលការអនុញ្ញាតចេញពីអារាម។

បងប្រុស ដាមីយ៉ាំង បានធ្វើការនៅព្រះសហគមន៍ជាច្រើន ដូចជា កំពង់គោ មាត់ក្រសាស់ តាអំ ចំណោម និងកំពង់ចាម។ គ្រប់ទីកន្លែងដែលបងប្រុសរស់នៅ គាត់យកចិត្តទុកដាក់ចំពោះអ្នកដទៃ ជាពិសេសយុវជន។ គាត់បានបកប្រែបទចម្រៀងពីភាសាឡាតាំងទៅជាភាសាខ្មែរ។ លោកមានបច្ចេកទេសខាងឱសថ ដែលអាចជួយដល់ប្រជាជនដែលមានជំងឺ។ លោកទទួលការគោរពពីពុទ្ធបរិស័ទ ជំរុញការយោគយល់និង សន្តិភាពក្នុងចំណោមមនុស្ស។ ចាប់ពីខែឧសភា ឆ្នាំ១៩៧០ រដ្ឋាភិបាលជម្លៀសជនជាតិវៀតណាមឲ្យទៅប្រទេសវៀតណាមវិញ។ ពេលនោះ ក្រុមបងប្រុសគ្រួសារដ៏វិសុទ្ធក៏បានទៅវៀតណាមដែរ ប៉ុន្តែ រូបគាត់មិនបានចាកចេញនោះទេ។

ដោយសង្គ្រាមរាតត្បាតកាន់តែខ្លាំង លោកអភិបាលបានហៅគាត់ ឲ្យទទួលខុសត្រូវនៅសាលាគ្រូអប់រំជំនឿ រួមជាមួយលោកឪពុក ហ្វ្រង់ស័រ ប៉ុងសូដ៏។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញ ហើយបង្ខំប្រជាជនឲ្យចេញទៅរស់នៅទីជនបទ។ បងប្រុសចេញដំណើរតាមផ្លូវជាតិលេខ៦ ឆ្ពោះទៅខេត្តកំពង់ធំ។ អង្គការខ្មែរក្រហមបានឲ្យគាត់ឈប់នៅភូមិសៀមរាង ជិតផ្សារតាំងគោក ហើយអ្នកស្រីដាំ ស៊ី បានហៅបងប្រុសមកស្នាក់នៅផ្ទះរបស់គាត់។ ក្រោយមក អង្គការខ្មែរក្រហមបានហៅគាត់ចេញពីគ្រួសារនោះទៅជាមួយតាអ៊ីត ដើម្បីទៅយាមចម្ការចេក ដែលមានចម្ងាយ២គីឡូម៉ែត្រពីផ្ទះ បងប្រុសនៅទីនោះប្រហែល០៦ខែ។ នៅឆ្នាំ១៩៧៨ ក្រោយចូលឆ្នាំខ្មែរបន្តិច អ្នកស្រីយកម្ហូបទៅឲ្យបងប្រុស ប៉ុន្តែមិនបានជួបគាត់ទេ។ ប្ដីរបស់គាត់និយាយថា៖ «តាដាមីយ៉ាំងត្រូវគេសម្លាប់ហើយ»។ តាំងពីពេលនោះមក អ្នកភូមិបានហៅទួលនោះថា៖ «ទួលតាមីយ៉ាំង»៕



ចម្ការដែលបងប្រុស ដាមីយ៉ាំង បានយាម
សព្វថ្ងៃគេហៅថា «ទួលតាញ៉ាំង» ជាឈ្មោះរបស់បងប្រុស។

## លោក យ៉ូសែប ថុង

ជាគ្រហស្ថ និង គ្រូអប់រំជំនឿ

(១៩៤៥-១៩៧៨)



លោក យ៉ូសែប ថុង កើតនៅឆ្នាំ១៩៤៥ មានដើមកំណើតនៅវៀតណាម ក្នុងទីក្រុងហាណូយ ជាក្មួយរបស់បងប្រុស ដាមីយ៉ាំង ដាំង ង៉ុក អាំង ហើយរស់នៅក្នុងភូមិកំពង់គោ ខេត្តកំពង់ធំ។ លោកសិក្សា និង អប់រំពីបងប្រុស ដាមីយ៉ាំង ហើយក្លាយទៅជាគ្រូអប់រំជំនឿ លោកជាជំនួយការលោកឪពុក រ៉ូប៊ែរ វីណេ (MEP) ដែលជាចៅអធិការនៅទីនោះ ទាំងការងារធ្វើស្រែ និងការអប់រំ។ លោករៀបការជាមួយស្ត្រីម្នាក់ឈ្មោះ អ៊ឹម សារឿន ជនជាតិខ្មែរ នៅភូមិកំពង់គោ ជាចុងភៅរបស់លោកឪពុក រ៉ូប៊ែរ វីណេ ហើយបង្កើតកូន៧នាក់។ លោកមិនដែលប្រើអំពើហិង្សាលើគ្រួសារ ហើយក៏មិនផឹកស្រា ឬជក់បារីឡើយ លោកតែងតែធ្វើជាគំរូដ៏ល្អដល់ប្រជាជន ដោយរស់នៅក្នុងគ្រួសារប្រកបដោយជំនឿ អប់រំបុត្រធីតាបានល្អស្របតាមជំនឿកាតូលិក និងតែងតែនាំកូនចៅទៅព្រះវិហារ។ លោកធ្លាប់និយាយថា៖ «ប្រសិនបើមានការលំបាកក្នុងជីវិតរបស់យើង ចូរទូលអង្វរព្រះជាម្ចាស់ចុះ!»។

នៅឆ្នាំ១៩៧០ មានទាហានវៀតកុងចូលភូមិ ហើយចាប់លោកបូជាចារ្យ រ៉ូប៊ែរ វីណេ លោក យ៉ូសែប ថុង ហ៊ានប្រថុយជីវិត ដោយប្រាប់ទាហានថា៖ «កុំប៉ះពាល់លោកឪពុកខ្ញុំ!» បន្ទាប់មក គាត់បានស្ម័គ្រចិត្តរួមដំណើរជាមួយគ្រីស្តបរិស័ទដែលត្រូវបានចាប់ខ្លួន នៅថ្ងៃនោះជាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧០។ ហើយនៅជាមួយពួកគេរហូតដល់ពេលត្រូវបានដោះលែង។ បន្ទាប់ពី ខ្មែរក្រហមបានកាន់កាប់ភូមិកំពង់គោទាំងមូល លោកបានផ្លាស់ទៅរស់នៅកំពង់ធំជាមួយគ្រួសារ។ នៅទីនោះ គាត់បានជួយដល់ជន-ភៀសខ្លួន ដោយធ្វើការជាពិសេសជាមួយអង្គការ Catholic Refugee Services។ នៅឆ្នាំ១៩៧៥ លោកត្រូវបានបង្ខំឲ្យទៅធ្វើការនៅស្រែជាមួយប្រជាជនទាំងមូល។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមចាប់លោកទៅ «សិក្សា» ដូចជនជាតិវៀតណាមទូទៅ ពេលនោះលោកលុតជង្គង់លាប្រពន្ធ ដោយបង្ហាញសេចក្ដីសង្ឃឹមចុងក្រោយគឺ ចង់ថ្វាយកូនម្នាក់ក្នុងចំណោមកូនទាំងអស់ ថ្វាយព្រះជាម្ចាស់ជាអ្នកបួស។ គុណធម៌សំខាន់របស់លោកគឺ ការលះបង់ដោយជួយបម្រើព្រះសហគមន៍ និងការយកចិត្តទុកដាក់ចំពោះគ្រួសារ៕



ព្រះវិហារកំពង់គោពីដើម



## បងស្រី ហ្សាកឺលីន គីម សួន

បព្វជិតាឧបការគុណ

(១៩១៧-១៩៧៥)

បងស្រី ហ្សាកឺលីន គីម សួន កើតនៅឆ្នាំ១៩១៧ នៅកម្ពុជាក្រោម (សព្វថ្ងៃនៅប្រទេសវៀតណាម)។ នៅឆ្នាំ១៩៣៧ បងស្រីបានចូលក្រុមគ្រួសារបព្វជិតាឧបការគុណ (Providence sister) ថ្វាយសច្ចានិរន្តរ៍ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៥២។ បងស្រីបំពេញបេសកកម្មជាបព្វជិតាបម្រើនៅព្រះសហគមន៍ "ព្រះនាងម៉ារីគ្មានជំពាក់បាប" ភូមិព្រះមាតា ទាំងកិច្ចការខាងព្រះវិហារនិងកិច្ចការធម៌មេត្តាករុណា បន្ទាប់មកបងស្រី ទៅបម្រើការងារនៅបាត់ដំបង។ ឆ្នាំ១៩៧៥ បងស្រី ហ្សាកឺលីន គីម សួន ទទួលបន្ទុកដ៏សំខាន់មួយគឺ មើលថែរក្សាកុមារកំព្រា។

ក្រោយខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ នៅខែ មេសា ឆ្នាំ១៩៧៥ បានបង្ខំឲ្យបងស្រីចេញពីបាត់ដំបង ជាមួយប្រជាជនទាំងមូល តាមសំណូមពររបស់លោកអភិបាល។ បងស្រីបាននាំយកទាំងកុមារកំព្រា១៥នាក់ ដែលកំពុងស្នាក់នៅទៅជាមួយ ហើយទៅរស់នៅក្នុងភូមិ អន្លង់រុន ប្រហែល ២៥ គីឡូម៉ែត្រ ពីទីក្រុងបាត់ដំបង។ នៅទីនោះ បងស្រីបានសាងសង់ខ្ទមស្មៅសម្រាប់រស់នៅ និងធ្វើការដាំដុះដីធ្លីរយៈពេលប្រហែល ៥ខែ។ នៅខែកញ្ញា ឆ្នាំ១៩៧៥ អង្គការខ្មែរក្រហមបានអនុញ្ញាតឲ្យទៅវៀតណាម ប៉ុន្តែដោយសារបងស្រី ហ្សាកឺលីន គីម សួន មានលក្ខណៈជាខ្មែរ គាត់មិនអាចចូលប្រទេសវៀតណាមបានទេ ហើយម្យ៉ាងទៀតមានកុមារកំព្រា ដែលត្រូវនៅជាមួយដែរនោះ បងស្រីក៏សុខចិត្តមកខ្មែរវិញ។ បន្ទាប់ពីថ្ងៃនោះមក ដំណឹងរបស់ពួកគេមិនបានដឹងច្បាស់ទេ ប៉ុន្តែ មានការសន្និដ្ឋានថា បងស្រីបានស្លាប់ ដោយសារភាពអត់ឃ្លាននៅកម្ពុជា ដោយសុខចិត្តលះបង់ជីវិត ដើម្បីកុមារកំព្រាទាំងនោះ៕



## បងស្រី លីឌី នូ សាវ៉ាន់

បព្វជិតាឧបការគុណ

(១៩៣១-១៩៧៧)

បងស្រី លីឌី នូ សាវ៉ាន់ កើតនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៣១ មកពីគ្រួសារធូធារ នៅខេត្តបាត់ដំបង។ នៅឆ្នាំ ១៩៤៩ បងស្រីចូលក្រុមបព្វជិតាឧបការគុណ បានថ្វាយសច្ចានិរន្តរ៍នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥៨។ បងស្រីបានបំពេញបេសកកម្មនៅព្រះវិហារ "ព្រះនាងម៉ារីគ្មានជំពាក់បាប" ភូមិព្រះមាតា។ នៅឆ្នាំ ១៩៦១ បងស្រីបានចាត់តាំងឲ្យទទួលខុសត្រូវ លើមណ្ឌលថែទាំកុមារមួយនៅទីក្រុងភ្នំពេញ។ ក្នុងពេលដំណាលគ្នានោះ បងស្រីជួយអប់រំយុវតី ក្នុងក្រុមណូវីស (Novices) ឬក្មេងស្រីដែលចង់រៀនបួស និងជួយណែនាំខាងផ្លូវវិញ្ញាណដល់ពួកគេ។

នៅឆ្នាំ១៩៦៧ បងស្រី លីឌី នូ សាវ៉ាន់ ទៅបម្រើការងារនៅភូមិកំពង់គោ ផ្នែកសុខ-ភាព ដោយមិនរើសអើងជំនឿ។ នៅឆ្នាំ១៩៧០ បងស្រីបានត្រឡប់មកទីក្រុងភ្នំពេញវិញដោយសារសង្គ្រាម។ ក្នុងអំឡុងពេលនោះ បងស្រីបានបង្ហាញសេចក្តីស្រឡាញ់បងប្អូនយ៉ាងខ្លាំងដោយយកចិត្តទុកដាក់ ជាពិសេសចំពោះក្រុមបងស្រីជនជាតិបារាំងដែលត្រូវបានបំបែកចេញពីនាង។ ទោះប្រឈមនឹងគ្រោះថ្នាក់ដល់ជីវិតក្តី នាងបានត្រឡប់ថយក្រោយ ដើម្បីយកអាហារទៅជួយពួកគេ។ ក្រោយមក បងស្រីត្រូវបញ្ជូនទៅមូលដ្ឋាននៅខេត្តកំពង់ធំ។ ដោយសារមានវ័យចំណាស់ អង្គការឲ្យបងស្រីធ្វើការក្នុងភូមិមើលកុមារតូចៗ។ នៅឆ្នាំ១៩៧៧ ថ្ងៃមួយខ្មែរក្រហម ឮបងស្រីច្រៀងបទឡាតាំង នឹងបទស្មូតលីតានៀ (Litania) ក៏ចាប់បងស្រីទៅសម្លាប់នៅភូមិដួង ខេត្តកំពង់ធំ៕



ផ្ទះបងស្រី ឧបការគុណ នៅភ្នំពេញ មុនសម័យសង្គ្រាម ឆ្នាំ១៩៧៥



ក្រុមបងស្រីឧបការគុណ



ក្រុមបងស្រីឧបការគុណ



## លោកបូជាចារ្យ
## យ៉ូហាន បាជ្រេ

បូជាចារ្យបព្វជិតបេណេឌីកតាំង

(១៩១៦-១៩៧៥)

លោក បូជាចារ្យ យ៉ូហាន បាជ្រេ កើតនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩១៦ នៅអារប័រ ក្នុងតំបន់យួរ៉ា ប្រទេសបារាំង។ លោកបានធំឡើងក្នុងគ្រួសារកាតូលិកមួយ ដែលក្នុងនោះមានបងប្អូនប្រុសពីរនាក់ជាបូជាចារ្យ។ នៅឆ្នាំ១៩៣៦ លោកចូល ក្រុមបព្វជិតបេណេឌីកតាំង «សន្ដីម៉ារី នៅឡាពីយែរ គីវៀរ»។ លោកបានថ្វាយពាក្យសច្ចាលើកដំបូង នៅឆ្នាំ១៩៣៨ ហើយបន្ទាប់មក លោកបានចូលបម្រើកាតព្វកិច្ចជាកងទ័ព។ ដោយសារសង្គ្រាម និងការបរាជ័យរបស់ប្រទេសបារាំង លោកត្រូវជាប់ពន្ធនាគារនៅប្រទេសអាល្លឺម៉ង់ រហូតដល់ឆ្នាំ១៩៤៥។ នៅទីនោះ លោកបង្ហាញចិត្តសប្បុរសជួយយកអាសារអ្នកទោសផ្សេងៗ និងផ្ដល់សេចក្ដីសង្ឃឹមឲ្យគេ។

លោកបាជ្រេ ទទួលអគ្គសញ្ញាតែងតាំជាបូជាចារ្យ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៤៨។ ក្នុងសមាជិកក្រុមបព្វជិតបេណេឌិកតាំង។ លោកត្រូវបានប្រធានចាត់ឲ្យទៅនៅវត្តអារាមនៅក្រុងដាឡាត ប្រទេសវៀតណាម ហើយចូលមកប្រទេសកម្ពុជានៅឆ្នាំ១៩៥៦ ស្នាក់នៅក្នុងវត្តអារាមក្រុងកែប ប្រទេសកម្ពុជា។ លោកស្វែងរករបៀបរស់នៅក្នុងអារាម ឲ្យស្របនឹងរបៀបបព្វជិតនៅអាស៊ី។ នៅឆ្នាំ ១៩៦៨ ដោយការអនុញ្ញាតពីចៅអធិការ លោកបានផ្លាស់ប្តូរមករស់នៅភូមិចំណោម ក្នុងខេត្តបន្ទាយមានជ័យ ដើម្បីបង្កើតក្រុមបព្វជិតនេះ ដោយបម្រើប្រជាជនក្នុងភូមិ។

សង្គ្រាមធ្វើឲ្យលោកផ្តល់សក្ខីភាពនៃសេចក្តីស្រឡាញ់ យ៉ាងច្រើនដល់ពួកខ្មែរក្រហម និងទាហានរដ្ឋាភិបាល និងប្រជាជនដែលរងគ្រោះដោយមិនខ្លាចអ្វីឡើយ។ ទីបំផុត ខ្មែរក្រហមចាប់លោកឪពុក យ៉ូហាន បាជ្រេ ជាមួយលោកអភិបាល ប៉ូល ទេព អ៊ីម សុត្ថា និងជនជាតិអូស្រ្តាលី យកទៅបាញ់សម្លាប់នៅស្រុកមង្គលបូរី នៅខែឧសភា ឆ្នាំ១៩៧៥៕

## លោក
## យ៉ូសែប សំ គីមសាន

គ្រហស្ថជំនួយការព្រះសហគមន៍

(១៩៤២-១៩៧៥)



លោក យ៉ូសែប សំ គីមសាន កើតនៅឆ្នាំ១៩៤២ នៅភូមិកំពង់គោ ខេត្តកំពង់ធំ ក្នុងគ្រួសារគ្រីស្តបរិស័ទ។ ដោយកំព្រាឪពុកម្តាយតាំងពីកាលនៅវ័យកុមារ លោកឪពុករ៉ូប៊ែរ វីណេ បានចិញ្ចឹមគាត់ដោយស្នាក់ក្នុងព្រះវិហារ។ នៅឆ្នាំ១៩៥៤ លោក យ៉ូសែប សំ គីមសាន មានអាយុ១២ឆ្នាំ លោកត្រូវបញ្ជូនឲ្យទៅរៀនសូត្រនៅអនុទេវវិទ្យាល័យនៅផ្សារតូច នៅទីក្រុងភ្នំពេញ។ ពេលវិស្សមកាល លោកតែងត្រឡប់ទៅភូមិកំពង់គោ ដើម្បីជួយអប់រំបង្រៀន និងធ្វើគង្វាលកិច្ចដោយមិនចេះនឿយហត់ ដូចជារៀបចំពិធីអាពាហ៍ពិពាហ៍ សម្អាតព្រះវិហារ ណែនាំអធិដ្ឋានមុនកម្មវិធី និងហាត់ចម្រៀង ។ល។

ឆ្នាំ ១៩៦៨ ទេវវិទ្យាល័យត្រូវបិទទ្វារ ពេលនោះលោកអភិបាល បានផ្ញើនិស្សិតទេវវិទ្យាល័យទៅបម្រើតាមព្រះសហគមន៍ផ្សេងៗ ដើម្បីឈ្វេងយល់អំពីវប្បធម៌ខ្មែរ។ ដោយការផ្ទុះសង្គ្រាមស៊ីវិល ទេវវិទ្យាល័យនៅកម្ពុជាមិនអាចដំណើរការឡើងវិញបានឡើយ។ នៅឆ្នាំ ១៩៧២ យ៉ូសែប សំ គីមសាន បានចូលបម្រើជាទាហាន តែមិនមែនទាហានជួរមុខទេ ដោយសារមានស័ក្តិ២ ដោយបានបោះបង់គំនិតក្លាយជាបូជាចារ្យ។ នៅឆ្នាំ១៩៧៤ លោកមានសិទ្ធិសុំភៀសខ្លួនទៅប្រទេសថៃ ប៉ុន្តែ ប្រពន្ធលោកបានទទួលដំណឹងអំពីការវាយប្រហារតាមអាកាស។ លោកសុខចិត្តបន្តនៅកម្ពុជាដោយនិយាយថា៖ «ខ្ញុំសុខចិត្តផ្ញើជីវិតទាំងស្រុងលើព្រះអង្គ»។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ។ ពួកខ្មែរក្រហមដឹងថា លោកជាគ្រីស្តបរិស័ទ និងជាទាហាន។ ពេលចេញពីទីក្រុងភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៥ ដល់ព្រែកក្តាម គេប្រាប់លោកឲ្យទៅទទួល ព្រះករុណា ព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ ប៉ុន្តែ នេះជាល្បិចរបស់ពួកគេ ដើម្បីយកទៅសម្លាប់។ ចាប់ពីពេលនោះមក គ្មានដំណឹង ឬឃើញលោកទៀតឡើយ។

គុណធម៌ដ៏សំខាន់របស់លោកគឺ ការយកចិត្តទុកដាក់ ស្រឡាញ់គ្រួសារ ជាពិសេសនៅគ្រាលំបាក។ ទោះបីគាត់មានឱកាសតែមិនគេចខ្លួនឡើយ៕


វត្តអារាមក្រុមបព្វជិតបេណេឌីកតាំង ក្រុងកែប


ទេវវិទ្យាល័យភ្នំពេញ



## លោក
## សិលា ឈុំ សំចៃ

គ្រហស្ថជំនួយការព្រះសហគមន៍

(១៩៣៣-១៩៧៧)

លោក សិលា ឈុំ សំចៃ កើតនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៣៣ នៅភ្នំពេញ ក្នុងគ្រួសារកាតូលិកមួយ នៅភូមិព្រះមាតា។ លោកសិក្សាខាងច្បាប់ ក្រោយមកជាមន្ត្រីរដ្ឋបាលផ្នែកក្រសួងពន្ធដារ។ ក្នុងតួនាទីនេះ លោកបានបម្រើនៅតួនាទី ជាច្រើននៅខេត្តផ្សេងៗ។ លោករៀបការជាមួយ អ្នកស្រី ហាណ្ណា នឿម យុកតាន់ ពីខេត្តបាត់ដំបង នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦០ មានកូនចំនួន១២នាក់ ដែលសុទ្ធតែជ្រមុជទឹកទាំងអស់ក្នុងព្រះវិហារ "ព្រះនាងម៉ារីគ្មានជំពាក់បាប" ភូមិព្រះមាតា។ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ លោក ឈុំ សំចៃ និងក្រុមគ្រួសារត្រូវគេជម្លៀសទៅជាមួយគេដែរ។

ស្នាដៃដែលបង្ហាញជំនឿរបស់លោក គឺជាកំណត់ហេតុក្នុងសៀវភៅគ្រួសារកាតូលិក សរសេរជាភាសាបារាំង អំពីដំណើរជីវិតក្នុងគ្រួសារ និងដំណើរស្លាប់របស់កូនៗ ដែលបានចាប់ផ្ដើមកត់ត្រា នៅខែមិថុនា ឆ្នាំ១៩៧៥ នៅពេលកូនរបស់លោកដែលមានអាយុ៥ឆ្នាំ និងមួយទៀតអាយុ៦ឆ្នាំ ត្រូវខ្មែរក្រហមយកទៅសម្លាប់។ គាត់រៀបរាប់ដំណើរស្លាប់របស់កូនៗទាំងនោះ ដោយបង្ហាញតាមរយៈជំនឿកាតូលិក គឺជីវិតមកពីព្រះជាម្ចាស់ ត្រូវផ្ញើទៅព្រះជាម្ចាស់ ឬអំពីជីវិតរស់ឡើងវិញដ៏រុងរឿងជាដើម។

៤ខែក្រោយមក ពួកខ្មែរក្រហមនាំលោកទៅភូមិមោង ខេត្តបាត់ដំបង។ គ្រួសារត្រូវខ្ចាត់ខ្ចាយបែកគ្នាទៅធ្វើការនៅកន្លែងផ្សេង។ កូនរបស់គាត់ដែលមានវ័យធំបន្តិច ត្រូវគេបញ្ជូនទៅធ្វើកងចល័ត។ កូនគាត់ស្លាប់៤នាក់នៅឆ្នាំ១៩៧៦ និង២នាក់ទៀតស្លាប់នៅឆ្នាំ១៩៧៧។ ប្រពន្ធគាត់ផ្ដល់សក្ខីភាពថា គាត់មិនសងសឹកពួកនោះទេ។ ព្រះជាម្ចាស់ប្រទានកូនមកលោក លោកក៏ថ្វាយកូននោះទៅព្រះជាម្ចាស់វិញ ទោះបីនឹកអាឡោះអាល័យយ៉ាងណាក៏ដោយក៏ជំនឿបានជួយលួងលោមលោក។ ថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៧៧ លោកត្រូវខ្មែរក្រហមចាប់ និងសម្លាប់៕



ព្រះសហគមន៍ព្រះនាងម៉ារីគ្មានជំពាក់បាប (ភូមិព្រះមាតា)



## លោកបូជាចារ្យ
## សិលា រ៉ាប៉ាំង

បូជាចារ្យសាសនទូតក្រៅប្រទេសនាក្រុងប៉ារីស

(១៩២៦-១៩៧២)

លោកបូជាចារ្យ សិលា រ៉ាប៉ាំង កើតនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩២៦ នៅទីក្រុង ឡឺប៊ូបែរ (Le Boupère) ប្រទេសបារាំង។ លោកបានចូលទេវវិទ្យាល័យនៅលូសុង (Luçon) ក្នុងឆ្នាំ១៩៤៦ ហើយនៅឆ្នាំ១៩៤៩ បានចូលជាសមាជិកក្រុមសាសនទូតក្រៅប្រទេសនាទីក្រុងប៉ារីស (MEP)។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៥៦ ហើយបានមកបំពេញបេសកកម្មនៅប្រទេសកម្ពុជានៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំដដែល។ នៅឆ្នាំ១៩៥៨ លោកបានរៀនភាសាវៀតណាមនៅបាណាម។ នៅឆ្នាំ១៩៥៩ លោកបានទទួលខុសត្រូវបម្រើព្រះសហគមន៍នៅស្រុកពាមជរ។ អស់រយៈពេលជិត១០ឆ្នាំ លោកបំពេញបេសកកម្មទាំងផ្នែកជីវិតខាងវិញ្ញាណ និងការងារសប្បុរសធម៌ ព្រមទាំងចំណាយពេលខ្លះចិញ្ចឹមមាន់។ នៅឆ្នាំ១៩៦៨ សន្ត-អាសនៈបានបែងចែកព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញជា៣ភូមិភាគ គឺភ្នំពេញ បាត់ដំបង និងកំពង់ចាម។ នៅឆ្នាំ១៩៦៩ លោកបានទៅបំពេញបេសកកម្មថ្មីនៅក្រូចឆ្មារ ក្នុងភូមិភាគកំពង់ចាម ដែលមានគ្រីស្តបរិស័ទខ្មែរ និងវៀតណាម។

នៅពេលសង្គ្រាមស៊ីវិលផ្ទុះឡើង ព្រះសហគមន៍ដែលលោកទទួលខុសត្រូវ ត្រូវបានកងកម្លាំងកុម្មុយនិស្តគ្រប់គ្រង។ ទោះបីមានការគំរាមកំហែងក៏ដោយ លោកបានសម្រេចចិត្តស្នាក់នៅជាមួយគ្រីស្តបរិស័ទ។ ចាប់ពីពេលនោះមក ការទំនាក់ទំនងជា-មួយលោកអភិបាលកាន់តែលំបាក។ ព្រះវិហារ និងផ្ទះលោកបូជាចារ្យក៏ត្រូវបានយន្ត-ហោះអាមេរិកទម្លាក់គ្រាប់បែក បង្ខំឱ្យលោកទៅជ្រកកោននៅក្នុងផ្ទះឈើមួយ។ ទោះយ៉ាងណា ដោយមានជំនួយពីបូជាចារ្យខ្មែរម្នាក់ និងក្រុមបងស្រីនៃក្រុមគ្រួសារបព្វជិតាឧបការគុណ លោកនៅតែអាចបន្តបេសកកម្មគង្វាលរបស់លោកបាន។

នៅយប់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧២ កងកម្លាំងកុម្មុយនិស្តបានដាក់គ្រាប់បែកក្រោមខ្ទមរបស់លោក សិលា រ៉ាប៉ាំង បណ្ដាលឱ្យលោករងរបួសធ្ងន់។ មុនពេលបាត់ស្មារតី លោកបានផ្ដាំកូនចៅកុំឱ្យសងសឹក និងបានលើកលែងទោសដល់អ្នកដែលប៉ុនប៉ងសម្លាប់លោក ព្រមទាំងប្រគល់ព្រះសហគមន៍របស់លោកថ្វាយព្រះជាម្ចាស់។ លោកត្រូវបានបញ្ជូនទៅព្យាបាលនៅក្រូចឆ្មារ ហើយបានទទួលមរណភាពនៅទីនោះ។ នៅ យប់ថ្ងៃទី២៤ ខែកុម្ភៈ សាកសពរបស់លោកត្រូវបាននាំត្រឡប់មកព្រះសហគមន៍វិញ និងបញ្ចុះនៅជិតព្រះវិហារភូមិក្តុលលើ៕



ពិធីបុណ្យសព លោកឪពុក សិលា រ៉ាប៉ាំង

# ព្រះវិហារថ្មីបំផុតនិងធំបំផុតនៅភូមិភាគភ្នំពេញមួយត្រូវបានឆ្លង

គ្រីស្តបរិស័ទរាប់រយនាក់ មកពីព្រះសហគមន៍កាតូលិកនានា ក្នុងភូមិភាគទាំងបីនៅក្នុងប្រទេស រួមនឹងភ្ញៀវជាតិនិងអន្តរជាតិ បានជួបជុំគ្នាប្រារព្ធពិធីឆ្លងព្រះវិហារ របស់ព្រះសហគមន៍ សន្តយ៉ូសែប ផ្សារតូច នារាជធានីភ្នំពេញ កាលពីចុងសប្តាហ៍កន្លងទៅនេះ។

ពីធីឆ្លងនេះ ត្រូវបានរៀបចំឡើងក្រោមអធិបតីភាពរបស់លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយលោកអភិបាល អេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង លោកអភិបាល សិលា សួន ហង្សលី អភិបាល ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម និងលោកអភិបាល ប៉ូល ត្រៃរ៉ុង ម្ទ្រី អភិបាលព្រះសហគមន៍ភូមិភាគស៊ូរ៉ាតថានីប្រទេសថៃ។ លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ នៅក្នុងពិធីថ្វាយអភិបូជា នាថ្ងៃបុណ្យឆ្លងព្រះវិហារកាលថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៦ ថា «នេះជាអំណោយដ៏ថ្លៃថ្លាបំផុត ដែលព្រះជាម្ចាស់បានប្រទានដល់ប្រជារាស្ត្រ ជាគ្រីស្តបរិស័ទ នៅព្រះសហគមន៍កាតូ-លិកនៅកម្ពុជា»។ លោកអភិបាល បានមានប្រសាសន៍បន្តថា ព្រះវិហារនេះជាព្រះវិហារស្អាតបំផុត ថ្មីបំផុត និង ធំបំផុតតំណាងឲ្យសិរីរុងរឿង នៃព្រះជាម្ចាស់នៅ ក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញ។

លោកអភិបាលបានបន្ថែមថា ព្រះវិហារនេះតំណាងឲ្យសេចក្តីស្រលាញ់ របស់ព្រះជាម្ចាស់ ចំពោះប្រជារាស្ត្ររបស់ព្រះអង្គនៅក្នុងប្រទេសកម្ពុជា។ លោកអភិបាល បានមានប្រសាសន៍បន្តទៀតថា នេះជាព្រះវិហារថ្មីដែលយើងបានសាងសង់បន្ត ពីអ្វីដែលនៅសេសសល់ និងការកកើតព្រះសហគមន៍កាតូលិកឡើងវិញ បន្ទាប់ពីរងការបំផ្លិចបំផ្លាញ នៅក្នុងសម័យប៉ុល ពត។ លោកបូជាចារ្យ ប៉ូល រឿង ឆ័ត្រសិរី ជាចៅ-អធិការព្រះវិហារសន្តយ៉ូសែប ផ្សារតូច និងជាអ្នកទទួលខុសត្រូវ មណ្ឌលសកម្មភាពភ្នំពេញខាងជើង បានមានប្រសាសន៍ថា «អស់រយៈពេលជាង៣៣ ឆ្នាំមកហើយ យើងបានប្រើប្រាស់អគារចាស់ជាព្រះវិហារពោលគឺតាំងពីឆ្នាំ១៩៩២ ដល់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៦ ទើបយើងបានទទួលអំណរសប្បាយជាមួយនឹងព្រះវិហារថ្មីដែលយើងបានឆ្លងនេះ»។

លោកបូជាចារ្យបានបន្តថា ព្រះវិហារនេះចាប់ផ្តើមគំនិតកសាងថ្មី នៅក្នុងឆ្នាំ២០១៨ ហើយត្រូវបានអនុម័តថវិកា ពីក្រុមសាសនទូតក្រៅប្រទេសនាទីក្រុងប៉ារីស នៅឆ្នាំ២០១៩។ ហើយក្នុងឆ្នាំ២០២០ ត្រូវបានបញ្ចុះបឋមសិលា និងបន្តសាងសង់។

ចំពោះដំណើរការសាងសង់ ព្រះវិហាថ្មីនេះ បានឆ្លងកាត់បញ្ហាជាច្រើនដូចជាការីករាលដាលនៃមេរោគកូវីដ ១៩ និង បញ្ហាជាច្រើនទៀត លោកចៅធិការព្រះវិហារបន្តថា ប៉ុន្តែនាថ្ងៃបុណ្យ ព្រះនាងព្រហ្មចារិនីម៉ារីគ្មានជំពាក់បាប នាថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៥ សរុប៤ឆ្នាំ ទើបព្រះវិហារនេះបានសាងសង់រួចរាល់។ អគារព្រះវិហារថ្មីនេះមានបណ្តោយ៤៨,៤ម៉ែត្រ ទទឹង៣០ម៉ែត្រ និង មានកម្ពស់ប្រមាណជា ៤៦ ម៉ែត្រ ដោយគិតចាប់ពីជាន់ផ្ទាល់ដី រហូតដល់កំពូលនៃព្រះវិហារ។ ព្រះវិហារនេះ កសាងតាមបែបរចនាបទខ្មែរបុរាណ រួមផ្សំនឹងរចនាបទក្នុងសម័យអាណានិគមបារាំង ដោយបានបញ្ចូលទស្សនៈគ្រីស្តសាសនា និងគំនិតទេវវិទ្យារបស់ព្រះសហគមន៍កាតូ-លិក ដើម្បីឲ្យអគារនេះ មានអត្តសញ្ញាណជាសំណង់ស្ថាបត្យកម្ម បែបព្រះសហគមន៍កាតូលិកកម្ពុជា។

ព្រះវិហារនេះ មានកន្លែងចំណតយានយន្ត សាលពហុមុខងារ ទីសក្ការៈសម្រាប់ប្រារព្ធពិធីថ្វាយអភិបូជា និង ពិធីនានា បន្ទប់បណ្ណាសារ និងតាំងពិពណ៌ ព្រមទាំងមានប៉មជួងព្រះវិហារ។

ពីមុនទីតាំងនេះ ជាអតីតអនុទេវវិទ្យា-ល័យនៃព្រះសហគមន៍កាតូលិក នៅកម្ពុជា ដោយទីនេះ មានអគាបុរាណមួយដែលបានសាងសង់តាំងពីឆ្នាំ១៩៣០៕

ដោយអរិយបុត្រ











# Ad Limina Visit 2026 របស់លោកអភិបាលកាតូលិកឡាវ-កម្ពុជា

ជារៀងរាល់១០ឆ្នាំម្តង លោកអភិបាលនៅទូទាំងពិភពលោក បានធ្វើដំណើរទៅកាន់ទីក្រុងរ៉ូម ដើម្បីចូលគាល់សម្តេចប៉ាប និងធ្វើសេចក្តីរាយការណ៍ អំពីកិច្ចការប្រ-កាសដំណឹងល្អ នៅក្នុងតំបន់ដែលពួកលោកទទួលខុសត្រូវ ដែលយើងតែហៅថា Ad Limina Visit។ ក្នុងជំនួបនៅឆ្នាំ ២០២៦ នេះសភាលោកអភិបាលនៃព្រះសហគមន៍កាតូលិកឡាវ-កម្ពុជា បានទៅទីក្រុងរ៉ូម ធ្វើទស្សនកិច្ច និងចូលគាល់សម្តេចប៉ាប និងជួបជូនរបាយការណ៍ដល់ក្រសួងនានា ដែលពាក់ព័ន្ធនឹងកិច្ចការប្រកាសដំណឹងល្អ នៅក្នុងប្រទេសទាំងពីរដូចខាងក្រោម៖











**ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៦៖**

- ក្រសួងសម្រាប់កិច្ចការបព្វជិត-ជិតា និងសមាគមសាសនទូត
- ក្រសួងក្រសួង វប្បធម៌ និងអប់រំ
- ក្រសួង សម្រាប់កិច្ចសន្ទនាអន្តរសាសនា
- ក្រសួង សម្រាប់កិច្ចការលើកកម្ពស់ការរួបរួមគ្នាជាធ្លុងតែមួយនៃគ្រីស្តបរិស័ទ





**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៦៖**

- គណៈកម្មាធិការ ការពារអនីតិជន
- ក្រសួងបូជាចារ្យ
- អគ្គលេខាធិការដ្ឋានកិច្ចការមហាសន្និបាទព្រះសហគមន៍







**ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៦៖**

- ក្រសួងពិធីបុណ្យ និងអគ្គសញ្ញានានា
- ក្រសួងកិច្ចការសន្តបុគ្គល
- ក្រសួងប្រកាសដំណឹងល្អ (នាយកដ្ឋានផ្នែកកិច្ចការធម្មទូតដំបូង និងព្រះសហគមន៍ថ្មីៗ)

**ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៦៖**

- ក្រសួងកិច្ចការគ្រហស្ថ ជីវិតគ្រួសារ និងជីវិត
- ក្រសួងសម្រាប់កិច្ចបម្រើការអភិវឌ្ឍន៍មនុស្សគ្រប់ជ្រុងជ្រោយ
- ក្រសួង គោលលទ្ធិនៃជំនឿកាតូលិក
- លេខាធិការដ្ឋាន សន្តសនៈ (បុរីវ៉ាទីកង់)

**ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦៖**

- **ចូលជួបសវនាការជាមួយសម្តេចប៉ាប ឡេអូ ទី១៤**
- ក្រសួងសារគមនាគមន៍ និងព័ត៌មាន

**ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៦៖**

- តុលាការកំពូល សន្តអាសនៈ



# លោកអភិបាល អូលីវីយេ ឆ្លុះបញ្ចាំងពីផ្លែផ្កា នៃ Ad Limina Visit នៅទីក្រុងរ៉ូម

បុរីវ៉ាទីកង់៖ ដំណើរបូជនីយចរ និងដំណើរទស្សនកិច្ចផ្លូវការ Ad Limina Apostolorum របស់សភាលោកអភិបាលកាតូលិកនៃប្រទេសឡាវ និងកម្ពុជា បានឈានមកដល់ទីបញ្ចប់ប្រកបដោយភាពនឹករលឹក និងពោរពេញដោយអំណរគុណព្រះជាម្ចាស់។ នៅក្នុងឱកាសបិទបញ្ចប់ពេលវេលាដ៏មានអត្ថន័យនេះ លោកអភិបាល អូលីវីយេ បានដឹកនាំការរិះគិតយ៉ាងស៊ីជម្រៅក្នុងអំឡុងពេលប្រារព្ធពិធីអភិបូជានៅវិសាលវិហារសន្តីម៉ារីមាយ័រ ទីក្រុងរ៉ូម ដែលជាវិសាលវិហារដ៏វិសេសវិសាលមួយឧទ្ទិសថ្វាយដល់ព្រះនាងព្រហ្មចារិនីម៉ារី។

នៅធម្មទេសនានោះ លោកអភិបាលបានគូសបញ្ជាក់ថា ដំណើរទស្សនកិច្ច Ad-Limina Apostolorum លើកនេះ មិនមែនគ្រាន់តែជាទស្សនកិច្ចការងារធម្មតានោះឡើយ ប៉ុន្តែ វាគឺជា «ដំណើរបូជនីយចរ» ដ៏ពិតប្រាកដទៅកាន់ផ្នូររបស់គ្រីស្តទូតពីដើម គឺគ្រីស្តទូតសិលា និងគ្រីស្តទូតប៉ូល។ ជាមួយគ្នានេះដែរ ការបញ្ចប់ដំណើរផ្លូវដ៏វិសុទ្ធនេះនៅចំពោះមុខព្រះនាងម៉ារី គឺជាការរំឭកអំពីបុគ្គលគំរូដ៏ឧត្តុង្គឧត្តមនៃភាពជាសាក្សី គង្វាល អ្នកបម្រើ និងអ្នកមានចិត្តបន្ទាបខ្លួន។ លោកអភិបាលក៏បានរំឭកផងដែរអំពីប្រវត្តិដ៏ចម្លែក និងពិសេសនៃវិសាលវិហារនេះ ដែលមានព្រិលធ្លាក់នៅថ្ងៃទី ១៥ ខែសីហា ដែលជាសញ្ញាដំបូងនៃការសាងសង់ឡើងដើម្បីឧទ្ទិសដល់ព្រះនាង។

លោកអភិបាល អូលីវីយេ បានបូកសរុបលទ្ធផល និងបទពិសោធន៍សំខាន់ៗដែលទទួលបានក្នុងរយៈពេលមួយសប្តាហ៍កន្លងមកនេះជាពីរកម្រិត៖

១. ការរួបរួមជាបងប្អូនយ៉ាងជ្រាលជ្រៅ៖ ការបានរស់នៅ និងចែករំលែកជីវិតប្រចាំថ្ងៃរួមគ្នារវាងលោកអភិបាលនៃប្រទេសឡាវ និងកម្ពុជា។

២. ការរួបរួមជាមួយព្រះសហគមន៍សកល៖ តាមរយៈកិច្ចពិភាក្សាជាមួយក្រសួងនានារបស់សន្តអាសនៈ។ លោកអភិបាលបានមានប្រសាសន៍ដោយក្តីរំភើបថា ទោះបីជាព្រះសហគមន៍នៅក្នុងស្រុករបស់យើង មានលក្ខណៈតូចតាច មើលទៅទន់ខ្សោយ និងមានកម្រិតយ៉ាងណាក៏ដោយ ក៏ជំនឿដ៏រស់រវើក និងរឹងមាំលើព្រះយេស៊ូ បានធ្វើឱ្យរដ្ឋមន្ត្រី និងសមាជិកនៃក្រសួងនានានៅបុរីវ៉ាទីកង់ មានការចាប់អារម្មណ៍ និងស្ញប់ស្ញែងយ៉ាងខ្លាំង។ ស្ថានភាពនេះត្រូវបានលោកអភិបាលប្រៀបប្រដូចទៅនឹង «ដំណើររបស់ពួកហោរាចារ្យ» ដែលបានធ្វើដំណើរពីទីឆ្ងាយដើម្បីមកថ្វាយបង្គំព្រះគ្រីស្ត និងឈរនៅចំពោះមុខព្រះសហគមន៍សកលដើម្បីធ្វើជាសាក្សីនៃសេចក្តីពិត។

ចំណុចលេចធ្លោបំផុតនៃដំណើរទស្សនកិច្ចនេះ គឺជំនួបសម្តែងការគួរសមជាមួយសម្តេច ប៉ាប ឡេអូ ទី១៤ ។ លោកអភិបាលបានរំឭកដល់បណ្តាំរបស់សម្តេចប៉ាបថា ទោះបីជាព្រះសហគមន៍នៅឡាវ និងកម្ពុជា ស្ថិតនៅសែនឆ្ងាយពីទីក្រុងរ៉ូមយ៉ាងណាក៏ដោយ ប៉ុន្តែជំនួបផ្ទាល់នេះបានផ្តល់នូវបទពិសោធន៍ជាក់ស្តែងនៃការរួបរួមគ្នាក្នុងជំនឿតែមួយ ជាគ្រួសារដ៏ធំតែមួយក្នុងពិភពលោក។

ជាចុងក្រោយ លោកអភិបាល អូលីវីយេ បានអំពាវនាវដល់គង្វាលទាំងអស់ នៅពេលត្រឡប់ទៅកាន់ព្រះសហគមន៍ភូមិភាគ និងប្រទេសរៀងៗខ្លួនវិញ ត្រូវរួមគ្នាចែករំលែកនូវអ្វីៗដែលបានឃើញ បានឮ និងព្រះអំណោយទានទាំងឡាយដែលបានទទួល។ លោកបានលើកយកព្រះបន្ទូលពីសារលិខិតរបស់សន្តយូដាសមកបញ្ជាក់ថា បេសកកម្មចម្បងគឺ «ការកសាងគ្នាទៅវិញទៅមកលើជំនឿដ៏វិសុទ្ធបំផុត អធិស្ឋានតាមព្រះវិញ្ញាណដ៏វិសុទ្ធ និងស្ថិតនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់» ដើម្បីនាំមកនូវក្តីសង្ឃឹមសម្រាប់ថ្ងៃនេះ និងថ្ងៃស្អែក។

មុននឹងបញ្ចប់ពិធី លោកអភិបាល និងគណៈប្រតិភូទាំងអស់ បានរួមគ្នាអធិដ្ឋាន និងផ្ញើជីវិត ក៏ដូចជាព្រះសហគមន៍ទាំងមូលទៅលើព្រះនាងព្រហ្មចារិនីម៉ារី ដែលជាអ្នកបម្រើ និងជាអ្នកគង្វាលដំបូងបង្អស់ ដែលបានទទួលដំណឹងល្អដើម្បីសូមព្រះអង្គប្រទានពរសេចក្តីសុខ និងថាមពលថ្មីក្នុងការបន្តបេសកកម្មប្រកាសដំណឹងល្អនៅក្នុងទឹកដីកម្ពុជា និងឡាវ តទៅមុខទៀត៕

ដោយ ស៊ីអេសស៊ី







